# ទិដ្ឋភាពទូទៅអំពីអ្នកតា និងជីវចលក្នុងសង្គមខ្មែរ

## តើអ្វីជាជំនឿលើអ្នកតា ឬជីវចល?

គ្រប់សាសន៍ទាំងអស់លើលោកភាគច្រើនតែងមានជំនឿផ្សេងៗតាំងពីបុរាណមករហូតដល់ការទទួលឥទ្ធិពលសាសនាហើយក៏ដោយ ក៏ការគោរព និងប្រតិបត្តិលើអ្នកតា ឬជិវចលនៅតែមានបន្តឥតដាច់ក្នុងផ្នត់គំនិតរបស់ពួកគេ។ ជំនឿលើអ្នកតា ឬជីវចលគឺសំដៅទៅលើការជឿ និងគោរពទៅលើអ្វីដែលគេគិតថាជាអ្នកគ្រប់គ្រងថែរក្សាស្រុកទេសមនុស្ស សត្វ និងអ្វីដែលជាធម្មជាតិជុំវិញខ្លួនមនុស្ស។ ក្នុងសម័យដើម ប្រជាជនខ្មែររស់លើតំបន់ខ្ពស់ និងឆ្ងាយពីគ្នាពីភូមិ មួយទៅភូមិមួយក្នុងភូមិភាគអាស៊ីអាគ្នេយ៍នេះឯងពោរពេញទៅដោយ ទន្លេ ដងអូរ ព្រៃភ្នំ ខ្មែរមានដើមកំណើតលើទឹកដីដ៏ស្រស់នេះជាម្ចាស់ ស្រុក ទើបជ្រើសយកទីខ្ពស់ដូចជាភ្នំ-ដំបូក-ទួល។ល។

## តើអ្នកតាមានដើមកំណើតមកពីណា?

យើងពុំដឹងច្បាស់អំពីវត្តមាននៃជំនឿលើជីវចល ឬអ្នកតាថាលេចឡើងក្នុងសង្គមខ្មែរតាំងពីពេលណាមកនោះទេ តែគេអាចដឹងថាមនុស្សលើលោកចាប់ផ្តើមជឿលើព្រលឹង ឬសេចក្តីស្លាប់តាមរយៈការអនុវត្តការកប់សពជាដើម។ ក្នុងតំបន់អាស៊ីអាគ្នេយ៍ ពិសេសក្នុងប្រទេសកម្ពុជា ការរកឃើញផ្នូរកប់សពចាស់ជាងគេអាចមានអាយុកាលរហូតដល់៤០០០ឆ្នាំមុនគ្រឹស្តសករាជ ដូចជាស្ថានីយបុរេប្រវត្តិសាស្ត្រល្អាងស្ពានជាដើម[១]។ នេះសបញ្ជាក់ឱ្យឃើញថា មនុស្សសម័យនោះបានមានជំនឿលើសេចក្តីស្លាប់ ឬជិវិតក្រោយសេចក្តីស្លាប់ អាចថាគេជឿលើព្រលឹងរបស់មនុស្ស។ ក្រោយមក ក្នុងសម័យដែលលេចចេញជាសង្គមខ្មែរមួយច្បាស់លាស់ ពេលខ្លះគេអាចដឹងតាមរយៈសិលាចារឹកដែលបង្ហាញថា ខ្មែរជឿលើអ្នកតា ដែលជាអធិធម្មជាតិ មានដូចជាភ្នំ ព្រៃ បឹង ទន្លេ និងរុក្ខជាតិផ្សេងៗផងដែរ។ ជាឧទាហរណ៍មួយ សិលាចារឹកអង្គរបុរី K.៦០០[២] មានកាលបរិច្ឆេទឆ្នាំ៦១១គ.ស បានបង្ហាញពីវត្តមានអ្នកតាក្នុងសង្គមខ្មែរ ដែលគេបានរៀបចំគ្រឿងរណ្តាប់សំរាប់សែនថ្វាយនោះគឺជាអ្នកតាដែលគង់នៅដើមរុក្ខជាតិម៉្យាងមានឈ្មោះថា សុក្រំ ដែលក្នុងសិលាចារឹក

[១] Sophady H. and all, 2015

[២] Cœdès, G., 1942:21-23

អត្ថបទដោយ៖ លោក សុខ កែវ សុវណ្ណារ៉ា

នោះគេហៅថា ***កម្រតាងអញតេមក្រម***។ យើងអាចនិយាយបានថា ដើមកំណើត ឬប្រភព នៃអ្នកតាភាគច្រើនចេញពីមូលហេតុសំខាន់ៗ៣ ដូចជា៖

***១.ធម្មជាតិ*** គឺសំដៅទៅលើអ្វីៗដែលផ្តល់ជាជម្រក ភោគផល និងភាពសំបូររុងរឿង ដល់អ្នកស្រុក ឧទាហរណ៍ភ្នំ ទន្លេ បឹង ត្រពាំង រុក្ខាជាដើម។ ក្នុងសង្គមខ្លះ ឬវប្បធម៌ខ្លះ គេជឿថាធម្មជាតិមួយចំនួនមានភាពរស់រវើក ឬដូចជាជីវិតមនុស្សសត្វដែលអាចមានញាណ អាចដឹងបាននូវអ្វីៗដែលនៅបរិស្ថានជុំវិញនោះ។ ដូចនេះហើយ ទើបគេជឿលើធម្មជាតិ ឬអធិធម្មជាតិ ដែលជាអ្នកផ្តល់នូវទីជម្រ អាហារ និងការលូតលាស់របស់មនុស្ស និងសត្វ មនុស្សជឿលើកំលាំងថាមពលរបស់ធម្មជាតិទាំងនោះ ប្រសិនបើធម្មជាតិណាមួយមានវិបត្តិឬបញ្ហា វានិងបង្កភាពមិនប្រក្រតីដល់ជីវិតមនុស្សសត្វដែរ។ ឧទាហរណ៍ កត្តាធម្មជាតិទាំងនោះ គឺទាក់ទងទៅនឹងធាតុទាំងសំខាន់៥លើលោក ដូចជា ទឹក (ភ្លៀង សមុទ្រ ទន្លេ ស្ទឹង បឹង...) ដី (ភ្នំ ទួល ដំបូក...) ភ្លើង ខ្យល់ និងឈើ (ព្រៃ)។ គេតែងបន់ជាដំបូងទៅដល់ធាតុទាំងនោះ ឧទាហរណ៍ការហៅខ្យល់ ឬភ្លៀងជាដើម ដោយមិនបាច់ប្រារព្ធធ្វើពិធីអ្វីធំទេ គឺគ្រាន់តែសំពះបែរបន់តាមមាត់ ឬក្នុងចិត្តក៏បានដែរ។

***២.មនុស្ស*** គឺសំដៅទៅលើបុគ្គលដែលមានសណ្តានចិត្តល្អ ឬអ្នកដែលហ៊ានលះបង់អាយុជីវិត ដើម្បីអ្នកស្រុក ឬជាតិ ក្រោយពេលបុគ្គលនោះស្លាប់ទៅ គេនៅរំលឹក និងគោរពបូជាដូចជាអ្នកតាដែរ។ ការសាងអំពីល្អ ឬការលះបង់ជីវិតក្នុងបុព្វហេតុជាតិ ឬធំណាមួយ រមែងធ្វើអោយអ្នកភូមិស្រុកគោរពចងចាំ ហើយជួនកាលបានសាងជារូបសំណាក ឬយកវត្ថុអ្វីមួយជាតំណាង ដោយគោរពដូចជាអ្នកតា ឬព្រលឹងដ៏មានរិទ្ធីអំណាចនៅថែរក្សាពួកគេផងដែរ (រូបលេខ១)។ ទិដ្ឋភាពបែបនេះ យើងឃើញមានច្រើនណាស់ក្នុងសង្គមខ្មែរ តាំងពីសម័យបុរាណ រហូតមកដល់បច្ចុប្បន្ន ឧទាហរណ៍ដូចជាការគោរពលើអ្នកតាឃ្លាំងមឿង អ្នកតាឪនៅព្រះវិហារ លោកយាយម៉ៅ (រូបលេខ២) ជាដើម។ ចំនុចនេះ គឺគេជឿខ្លាំងទៅលើព្រលឹងរបស់មនុស្ស ដែលខុសបន្តិចពីការគោរពប្រត្តិបត្តិលើធម្មជាតិ។

***គ.ទេព*** គឺសំដៅលើការកែប្រែពីទេពនៅក្នុងសាសនា ដែលធ្លាប់មានក្នុងសង្គមពីបុរាណ ហើយត្រូវបានគេគោរពដូចជាអ្នកតានាពេលបច្ចុប្បន្ន។ ក្នុងសម័យបុរាណ ខ្មែរមានការគោរពយ៉ាងមុតមាំលើសាសនា ពិសេសពុទ្ធសាសនាមហាយាន និងហិណ្ឌូសាសនា

អត្ថបទដោយ៖ លោក សុខ កែវ សុវណ្ណារ៉ា

ដោយមានទេពជាច្រើនត្រូវបានគេបូជា និងគោរព ដោយរួមមានទាំងការស្ថាបនាបដិមានានាតំណាងអោយទេពទាំងនោះផង។ ដោយមានការផ្លាស់ប្តូររបត់សង្គម និងសាសនា ការគោរពលើទេពក្នុងសាសនាមុនៗបានសាបរលាប តែបដិមាមួយចំនួនត្រូវកែប្រែឱ្យទៅជាទេពក្នុងសាសនាថេរវាទ ហើយមួយចំនួនតូចត្រូវបានចាត់ទុកថាជារូបតំណាងឱ្យអ្នកតាក្នុងស្រុកភូមិរបស់ពួកគេវិញ។ យ៉ាងណាមិញ ការផ្លាស់ប្តូរបែបនេះ យើងឃើញមាននៅតាមតំបន់មួយចំនួនដែលធ្លាប់ជាទីប្រជុំជនសំខាន់ៗនាសម័យបុរាណ ជាទីទួលប្រាសាទដែលបានរលំបែកបាក់ហើយ ត្រូវបានគេប្រមូលគរទុកនូវពល់បំណែកចំលាក់សំខាន់ៗទាំងឡាយ រួចសង់ខ្ទមប្រក់ពីលើធ្វើជាអ្នកតា។ ទេពសំខាន់ៗមួយចំនួនដែលត្រូវបានបាត់បង់អត្តសញ្ញាណ ឬពុំត្រូវបានស្គាល់ដោយមនុស្សសម័យក្រោយ ក៏ត្រូវបានឧបកិច្ចជាអ្នកតា ឬលោកយាយផងដែរ។ ជាឧទាហរណ៍ ដូចជារូបសំណាក់លោកយាយទេពនៅខេត្តសៀមរាប ដែលជាបដិមាដើមគឺជាព្រះយមរាជ។ ឧទាហរណ៍១ទៀត លោកតារាជ្យនៅអង្គរវត្ត (រូបលេខ៣) ដើមឡើយជាអវលោកិតេស្វរៈក្នុងពុទ្ធសាសនាមហាយានក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។

## រឿងព្រេងមួយចំនួនទាក់ទងនិងប្រវត្តិអ្នកតា

ដោយសារតែជំនឿ និងការទាក់ទាញឱ្យអ្នកដទៃជឿក្នុងជំនឿរបស់ខ្លួន ឬតំបន់របស់ខ្លួន រឿងព្រេងជាច្រើនត្រូវបានគេបង្កើតឡើង ដោយពុំមានប្រភពច្បាស់លាស់ ជួនកាលគ្រាន់តែជាការនិយាយតៗគ្នារៀងមក។ រឿងព្រេងទាំងនោះមានដូចជា៖ ប្រវត្តិអ្នកតាឃ្លាំងមឿងអ្នកតាកងជុំ អ្នកតាម៉ឹនគង់ អ្នកតាត្រដោល អ្នកតាពុំសែន អ្នកតាគណេស អ្នកតាទួលស៊ឹង អ្នកតាយាយខ្មៅ អ្នកតាភ្នំជី អ្នកតាទ្វារសុក អ្នកតាបាពាល រឺព្រះកន្ទោង អ្នកតាសិង្ហនិងអ្នកតាព្រះឥន្ទ្រ អ្នកតាសំពៅធ្លាយ អ្នកតាមេសនៅស្រុកបាភ្នំ អ្នកតាមហេសក្ខ ឬអ្នកតាមាតគិត អ្នកតាបេង អ្នកតាតាស្រី និងយាយបុស អ្នកតាក្រហមក អ្នកតាជំទាវម៉ៅ អ្នកតាកង្ហារដែក អ្នកតាព្រះគណេស អ្នកតាយាយង៉ួន អ្នកតាយាយខ្មៅ (នៅស្រុកបាសាក់ ភូមិសង្កែ ឃុំទ្រៀងខាញ ខេត្តឃ្លាំង) អ្នកតាតាលាក់ អ្នកតាតាថង អ្នកតាតានុង អ្នកតាព័ទ្ធសាឡី និងអ្នកតាតន់ជាដើម។

អត្ថបទដោយ៖ លោក សុខ កែវ សុវណ្ណារ៉ា

# អត្ថបទ៖ ទិដ្ឋភាពទូទៅអំពីអ្នកតា និងជីវចលក្នុងសង្គមខ្មែរ

ប្រភេទ ឬឋាន:អ្នកតា

ជាធម្មតា មនុស្សរស់នៅតាមតំបន់ផ្សេងគ្នា តែងតែមានការគោរពខុសគ្នាបន្តិចបន្តួចលើអ្នកតា។ តែជាទូទៅ សំរាប់ជនជាតិខ្មែរ អ្នកតាទាំងឡាយច្រើនទទួលបានតាមការគោរពពីអ្នកក្នុងតំបន់ និងអ្នកដែលបានដឹង និងទៅដល់។ ចំនុចនេះ យើងឃើញថា ក្នុងសង្គមខ្មែរមានការគោរពលើអ្នកតាផ្សេងៗ រួមមានអ្នកតាភ្នំ អ្នកតាព្រៃ អ្នកតាចាស់ស្រុក អ្នកតាទឹក អ្នកតាដី អ្នកតារុក្ខា អ្នកតាទិសជាដើម។ អ្នកតាទាំងនោះមានឋាន:ដូចគ្នាៗ តែគ្រាន់តែគង់នៅតាមតំបន់រៀងៗខ្លួន និងមានតួនាទីផ្សេងៗគ្នាដែរ។

### ក.អ្នកតាចាស់ស្រុក

អ្នកតាចាស់ស្រុកគឺសំដៅទៅលើអ្នកតាដែលធំជាងគេក្នុងស្រុក ឬភូមិ ដែលមានតួនាទីជាអ្នកថែរក្សាស្រុកភូមិ មនុស្ស និងសត្វពាហន:ទាំងឡាយ។ អ្នកតាចាស់ស្រុកច្រើនកើតចេញពីបុគ្គលដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងស្រុកភូមិ ភាគច្រើនជាមេទ័ពសម័យបុរាណ ដែលគេគិតថាជាអ្នកខ្លាំងពូកែបានជួយសង្គ្រោះដល់មាតុភូមិ ហើយនៅពេលស្លាប់ទៅត្រូវបានគេគោរព និងជឿថាព្រលឹងរបស់គាត់បានក្លាយជាអ្នកតាដែលមានឫទ្ធិអំណាចអាចការពារភូមិស្រុកនិងមនុស្សតទៅទៀតបាន។ អ្នកតាចាស់ស្រុកមានស្ទើរគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ពិសេសនៅតាមភូមិដ្ឋានដែលជាស្ថានីយបុរេប្រវត្តិសាស្ត្រ ឧទាហរណ៍ភូមិមូល គឺអ្នកតាចាស់ស្រុករបស់គេច្រើនតែនៅចំផ្ចិតកណ្តាលនៃភូមិ និងតាមតំបន់ជនជាតិភាគតិច គឺច្រើននៅតាមជាយភូមិ ឬក្នុងព្រៃក្បែរភូមិកររបស់គេ។ នៅតំបន់ខ្លះ គេហៅអ្នកតាចាស់ស្រុកថា អ្នកតាគង់ស្រុកផងដែរ (រូបលេខ២)។

### ខ.អ្នកតាភ្នំ

អ្នកតាភ្នំ គឺសំដៅអ្នកតាដែរនៅថែរក្សា ឬគ្រប់គ្រងតំបន់ភ្នំ។ អ្នកតាភ្នំមានប្រភេទពីរ គឺអ្នកតាភ្នំដែលគេគោរពនិងដាក់ឈ្មោះអោយជាលក្ខណ:ធម្មជាតិ និងអ្នកតាភ្នំដែលកើតឡើងពីមនុស្ស ឬបុគ្គលណាមួយ។ ក្នុងប្រទេសកម្ពុជាយើងនេះ អ្នកតាភ្នំមានស្ទើរគ្រប់តំបន់ណាដែលមានភ្នំ ជួនកាលនៅលើភ្នំតែមួយគឺអាចមានអ្នកតាពីរ ឬច្រើនទៀតផង។ គេច្រើនធ្វើការបន់ស្រន់ដល់អ្នកតាភ្នំនៅពេលគេទៅលេងកំសាន្ត ពិសេសគឺដំណើរស្វែងរកសត្វ ឬរុក្ខជាតិនានា។

អត្ថបទដោយ៖ លោក សុខ កែវ សុវណ្ណារ៉ា

### គ.អ្នកតាទឹក

អ្នកទឹកគឺសំដៅលើអ្នកតាដែលរក្សានៅតាមបឹងបួរ អូរ ស្ទឹង ទន្លេ និងសមុទ្រ។ អ្នកខ្លះបានចាត់ទុកថា ឬហៅអ្នកតាទឹកថា អារក្ខទឹក គឺជាអ្នកដែលនៅចាំយាមនៅក្នុងទឹក។ អ្នកស្រុកមួយចំនួនជឿថា នៅពេលមានមនុស្សលង់ទឹកលិចបាត់រកមិនឃើញ គេតែតែងធ្វើពិធីបួងសួងសុំដល់អារក្ខទឹកប្រគល់មនុស្សដែលលង់ទឹកនោះមកវិញ ព្រោះគេជឿថាអារក្ខទឹកបានលាក់រូបកាយរបស់បុគ្គលនោះ ដោយសារបុគ្គលនោះបានប្រព្រឹត្តិខុសដោយទង្វើ ឬដោយពាក្យសំដីអ្វីមួយ។ ចំពោះប្រជានេសាទទាំងទឹកសាប និងទឹកសមុទ្រ គេតែងធ្វើការបួងសួងដល់អ្នកតាទឹក ដើម្បីអោយគេបានទទួលសុខសប្បាយ និងភោគផលពីការនេសាទរបស់ពួកគេ។

### ឃ.អ្នកតាដី

អ្នកតាដីគឺសំដៅលើអ្នករក្សាដីធ្លី ផ្ទះសំបែង គឺគេអាចហៅថាព្រះភូមិ។ ព្រះភូមិ ឬអ្នកតាដី ជាទូទៅមានច្រើន ពោលគឺនៅតាមផ្ទះមួយ គេតែងនិមន្តអញ្ជើញអ្នកតាម្នាក់អោយមកធ្វើជាព្រះភូមិរបស់ពួកគេ ដោយមានតួនាទីរក្សាភូមិករ ផ្ទះសំបែងនៅក្នុងព្រំរបងជាកំណត់។ ជាធម្មតា គេតែងធ្វើរានតូចមួយ ឬជាផ្ទះតូចមួយដែលទ្រដោយសសរមួយដើម ឧទ្ទិសដល់អ្នកតាដី ហើយផ្ទះឬរាននោះជាទូទៅគឺត្រូវបែររកទ្វារចូលផ្ទះ។ អ្នកតាដីឬព្រះភូមិត្រូវបានគេគោរពយ៉ាងខ្ជាប់ខ្ជួន ទាំងនៅជនបទ និងទីក្រុង។ នៅតំបន់ខ្លះ អ្នកតាដីឬព្រះភូមិត្រូវបានគេអញ្ជើញអោយមកចាំរក្សាដីធ្លីនៅពេលអាចារ្យរៀបចំធ្វើពិធីសែនក្រុងពាលីមុនសាងសង់ផ្ទះសំបែង។

### ង.អ្នកតាដើមឈើ ឬអ្នកតាព្រៃ

អ្នកតាដើមឈើ ឬអ្នកស្រុកខ្លះហៅថា អារុក្ខទេវតា គឺជាអ្នករក្សានៅតំបន់ព្រៃធំៗ។ ជាទូទៅ អ្នកតាដើមឈើតែងតែពួកស្នាក់អាស្រ័យនៅតាមដើមឈើធំៗដែលមានមែកម្ញប់ត្រសុំត្រសាយ ដូចជាដើមពោធិ ឬដើមជ្រៃជាដើម។ គេច្រើននាំគ្នាសន្មតថា ទេព្រ័ក្ស[1] អ្នកតាទាំងនោះស្នាក់នៅអាស្រ័យនៅលើដើមឈើធំខ្ពស់ជាងគេ នៅលើថ្មធំ នាកំពូលភ្នំ ឬនៅត្រពាំងធំនៅក្នុងព្រៃនោះៗ ការសន្មតនេះពុំមានកិច្ចជានាជាក់លាក់ ធ្វើឱ្យអ្នកស្រុក

[1] ជួន ណាត, ១៩៦៧:៤៥០

កត់ សម្គាល់ច្បាស់លាស់ថា កន្លែងនោះ ពិតជាលំនៅឋានរបស់អ្នកតានោះឡើយ។ គេនៅតែមានការសង្ស័យជាប់ជានិច្ច គឺក្នុងស្មារតីចង់ដឹងច្បាស់លាស់ ចង់ឃើញទីតាំងពិតប្រាកដរបស់ទេព្រ័ក្ស អ្នកតានេះហើយ បានជាមានផុះគំនិតឧបកិច្ចឱ្យកើតមានទីលំនៅរបស់អ្នកតាព្រៃ[2]។

សរុបមក នេះជាសេចក្តីសង្ខេបអំពីទិដ្ឋភាពអ្នកតាឬជីវចលក្នុងសង្គមខ្មែរ ដែលតែងតែឋិតនៅក្នុងផ្នត់គំនិតប្រជាជនជាប់ជានិច្ច។ ការគោរព និងប្រតិបត្តិចំពោះអ្នកតាតែងមានលក្ខណៈខុសគ្នាតិចតួចតាមតំបន់ និងឋានៈ។

ឯកសារពិគ្រោះ

**ជួន ណាត**

១៩៦៧. *វចនានុក្រមខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

**មៀច ប៉ុណ្ណ**

១៩៩៤. កម្រងឯកសារស្តីពីប្រពៃណីនិងទំនៀមទម្លាប់ខ្មែរ, ភាគ១, ភ្នំពេញ។

Cœdès, G.

1942. *Inscription du Cambodge*, Volume II, Hanoi.

**Sophady H. and all,**

2015. *Laang Spean Cave (Battambang Province): A Tale of Occupation in Cambodia from Late Upper Pleistocene to Holocene*, Article in Press

[2] មៀច ប៉ុណ្ណ:១៩៩៤



រូបលេខ១៖ អ្នកតាកើតចេញពីមេទ័ព



រូបលេខ២៖ អ្នកតា យាយម៉ៅ (ពេជ្រនិល)



រូបលេខ៣ អ្នកតាកើតចេញពីទេព (តារាជអង្គរវត្ត)



រូបលេខ៤ អ្នកតាគង់ស្រុក (ព្រៃវែង)